CDRI
Cambodia Development Resource Institute

IDRC | CRDI
International Development Research Centre
Centre de recherches pour le développement international

Canada

សង្ខេបសម្រាប់
គោលនយោបាយ

មីនា ២០១៩ លេខ ០៧

# ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការប្រែប្រួលក្នុងទីផ្សារពលកម្ម សម្រាប់ក្រុមយុវជនស្ថិតនៅក្នុងស្ថានភាពសេដ្ឋកិច្ចលំបាកនៅកម្ពុជា

## សេចក្តីផ្តើម

កង្វះជំនាញតែងសំគាល់បានថាជាកត្តាកំណត់សំខាន់មួយនៃភាពគ្មានការងារធ្វើ ភាពក្រីក្រ និងអសន្តិសុខក្នុងសង្គម និងជាឧបសគ្គធំមួយដល់ការរីកចម្រើននៃបណ្តាប្រទេសកំពុងអភិវឌ្ឍន៍។ ដើម្បីបង្កើនចំនួនជនពេញវ័យមានការងារធ្វើជាផ្លូវការ អ្នកទាំងនោះចាំបាច់ត្រូវមានជំនាញស្របតាមតម្រូវការទីផ្សារ។ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ជាវិធីសាស្ត្រល្អមួយសម្រាប់ជួយជនពេញវ័យ ជាពិសេសអ្នកមានស្ថានភាពលំបាកខាងសេដ្ឋកិច្ច ឬឆាប់បោះបង់ការសិក្សា ដើម្បីឲ្យកសាងជំនាញការងារមួយចំនួន។

កម្លាំងពលកម្មក្នុងប្រទេសកំពុងអភិវឌ្ឍភាគច្រើន ជាពលករមានជំនាញទាប និងមានវ័យក្មេងអាយុពី ១៥ ទៅ ៣០ឆ្នាំ (ក្រុមយុវជន) ដែលភាគច្រើន ជាជនគ្មានការងារធ្វើ ឬមួយជាប់ផុងក្នុង ការងារក្រៅផ្លូវការបានប្រាក់កម្រៃទាប។ នៅកម្ពុជា ក្រុមយុវជនមានប្រមាណ ៣៣% នៃប្រជាជនសរុបក្នុងឆ្នាំ២០១៤។ ទោះបីមានក្រុមយុវជនដ៏ធំបែបនេះជាសក្តានុពលមួយក្តី ប៉ុន្តែវាក៏ជាបញ្ហាប្រឈមចម្បងមួយដល់លទ្ធភាពមានការងារធ្វើ។

នៅឆ្នាំ២០១៤ អត្រាចូលរួមក្នុងកម្លាំងពលកម្មរបស់ក្រុមយុវជនមានប្រមាណ ៧៧% ក្នុងនេះយុវជនដែលបម្រើការងារទទួលបានប្រាក់ឈ្នួលមានប្រមាណ ៦០%។ ជាមធ្យម កម្រិតអប់រំរបស់យុវជនមានចំនួន ៧,៣ឆ្នាំ។ សិស្សក្នុងគ្រួសារមានចំណូលទាប ងាយបោះបង់ការសិក្សាជាងគេ ដើម្បីជួយធ្វើការនៅផ្ទះ ឬក៏ទៅរកប្រាក់ចំណូលមកជួយទ្រទ្រង់ជីវភាពគ្រួសារ ពីព្រោះតម្លៃឱកាសបាត់បង់ ដោយសារការទៅរៀននៅសាលាវាមានកម្រិតខ្ពស់ពេក។ ដូចនេះ យុវជនជារឿយៗចូលរួមក្នុងកម្លាំងពលកម្ម ដោយគ្មានជំនាញមូលដ្ឋានអ្វីសោះ។

កន្លងមក រាជរដ្ឋាភិបាលកម្ពុជាបានប្រឹងប្រែងជាខ្លាំងដើម្បីកែលំអលទ្ធភាពមានការងារធ្វើរបស់យុវជន ដូចជា តាមរយៈយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាព និង ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រឆ្នាំ២០១៤-២០១៨ នៃការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។ ទោះបីជាយ៉ាងនេះក្តី ត្រូវមានការប្រឹងប្រែងច្រើនថែមទៀត ជាពិសេសក្នុងការកែលំអកម្លាំងពលកម្មដែលមានជំនាញ បើសិនកម្ពុជាចង់ដើរឲ្យទាន់ប្រទេសអាស៊ានឯទៀត ក្នុងការអនុវត្តតាមគោលការណ៍របស់សហគមន៍សេដ្ឋកិច្ចអាស៊ាន។

ការបណ្តុះបណ្តាលមានអាទិភាពខ្ពស់បំផុត ក្នុងផែនការអភិវឌ្ឍន៍ជាតិ។ ប៉ុន្តែមានភស្តុតាងតិចតួចណាស់ដែលបង្ហាញពីប្រសិទ្ធភាពនៃ ការបណ្តុះបណ្តាលនៅតាមប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងការជួយឲ្យយុវជនទទួលបានការងារផ្លូវការនៅក្នុងទីផ្សារពលកម្ម។ ភស្តុតាងតាមការស្រាវជ្រាវបែបពិសោធន៍ជាក់ស្តែង (experimental method) រឹតតែមានតិចតួចណាស់ទៀត ហើយការវាយតម្លៃកន្លងមកទៅលើប្រសិទ្ធភាពនៃកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈផ្សេងៗក៏មិនបានផ្តល់លទ្ធផលច្បាស់លាស់គ្រប់គ្រាន់នៅឡើយ។

អត្ថបទសង្ខេបគោលនយោបាយនេះ ផ្អែកលើការសិក្សាពីឥទ្ធិពលនៃ ការចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈមួយសម្រាប់ក្រុមយុវជនមកពី គ្រួសារមានប្រាក់ចំណូលទាប (Ouch 2019) ដោយផ្តោតលើ ផលប៉ះពាល់នានានៃកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ ទៅលើលទ្ធភាពទទួលបានការងារធ្វើ និងឧបសគ្គផ្សេងៗក្នុងការទទួលយក និងបញ្ចប់ការបណ្តុះបណ្តាលទាំងស្រុង។ អ្នកស្រាវជ្រាវក៏បានកត់ត្រាពីបញ្ហាប្រឈម និងបទពិសោធន៍បានពីការចុះធ្វើការជាមួយក្រុមយុវជន ដែលស្ថិតក្នុងស្ថានភាពសេដ្ឋកិច្ចលំបាក និងគ្រួសាររបស់ពួកគេ។ ទាំងអស់នេះបានផ្តល់ព័ត៌មានដ៏មានប្រយោជន៍ និងបង្ហាញពីផលពាក់ព័ន្ធផ្សេងៗ ដើម្បីជួយឲ្យប្រទេសកំពុងអភិវឌ្ឍន៍នានា អាចរៀបចំកម្មវិធីបណ្តុះបណ្តាល និងគោលនយោបាយមុខរបរ និងការងារ ឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

## ការសិក្សាស្រាវជ្រាវ

ការសិក្សាវាយតម្លៃតាមបែបពិសោធន៍ជាក់ស្តែង ពីផលប៉ះពាល់នៃកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈនានា ជាវិធីសាស្ត្រស្រាវជ្រាវថ្មីមួយនៅកម្ពុជា។

រៀបរៀងដោយបណ្ឌិត អ៊ូច ច័ន្ទតារ៉ានី ជាអ្នកស្រាវជ្រាវ និងប្រធានផ្នែកសេដ្ឋកិច្ចនៅវិទ្យាស្ថាន CDRI។ សូមយោងឯកសារនេះថា៖ Ouch Chandarany. 2019. *Vocational Training and Labour Market Transitions of Cambodian Disadvantaged Young Adults*. GMS-Net Policy Brief 2019 No. 07. Phnom Penh: CDRI.

## អន្តរាគមន៍ក្នុងការសិក្សា

អន្តរាគមន៍ក្នុងការសិក្សានេះ គឺ ការផ្តល់ការបណ្តុះបណ្តាលជំនាញគេហកិច្ច (ការរៀបចំបន្ទប់) រយៈពេលពីរខែ ដោយផ្តោតលើ៖ ក្រុមយុវជនអាយុពី ១៥-៣០ឆ្នាំ កំពុងរស់នៅតាមកន្លែងអនាធិបតេយ្យ ក្នុង ៩ខណ្ឌ នៅរាជធានីភ្នំពេញ (ដែលមានសរុប ១២ខណ្ឌ) និងចេះអាន ចេះសរសេរ ហើយពេញចិត្តចូលរួមក្នុងការបណ្តុះបណ្តាល។ វគ្គបណ្តុះបណ្តាលជំនាញរៀបចំបន្ទប់ ត្រូវបានជ្រើសយកពីព្រោះមានតម្រូវការច្រើនក្នុងវិស័យទេសចរណ៍ អ្នកមានការអប់រំទាបក៏អាចចូលរួមបាន ហើយសមស្របសម្រាប់ទាំងបុរស និងស្ត្រី។ វគ្គបណ្តុះបណ្តាលនេះបានរៀបចំ និងអនុវត្តឡើងដោយសហការជាមួយ អង្គការដើម្បីស្នាមញញឹមនៃកុមារ (PSE) និងរួមមាន ការសិក្សាមេរៀនក្នុងថ្នាក់ ១៨០ម៉ោង និងការអនុវត្តជាក់ស្តែង ១៨០ម៉ោង។ សិក្ខាកាមត្រូវរៀនពីថ្ងៃច័ន្ទ ដល់ សុក្រ ពីម៉ោង ៧:០០ព្រឹក ដល់ថ្ងៃត្រង់ និងពីម៉ោង ២:០០ ដល់ ៥:០០ល្ងាច និងនៅថ្ងៃសៅរ៍ ពីម៉ោង ៧:០០ព្រឹក ដល់ថ្ងៃត្រង់។

វគ្គបណ្តុះបណ្តាលនេះបានដំណើរការបួនលើក ក្នុងចន្លោះពេលពីខែមិថុនា ដល់ខែកញ្ញា ឆ្នាំ២០១៦ ដោយមានគ្រូបង្រៀនកម្មវិធីសិក្សានិងបរិយាកាសសិក្សាដូចគ្នាទាំងអស់។ អ្នកចូលរួមទទួលបានឯកសណ្ឋានមួយសម្រាប់ អាហារថ្ងៃត្រង់ សម្ភារសិក្សា និង អង្ករ ៣,៥គ.ក្រក្នុងមួយសប្តាហ៍ ប៉ុន្តែគ្មានប្រាក់ឧបត្ថម្ភប្រចាំថ្ងៃទេ។សិក្ខាកាមដែលរស់នៅតាមផ្លូវរថយន្តដឹកសិស្សរបស់អង្គការ PSE អាចទទួលបានដោយឥតគិតថ្លៃនូវសេវាជួយដឹកជញ្ជូនទៅមក ប៉ុន្តែសម្រាប់សិក្ខាកាមនៅវគ្គទី៣ និងទី៤មានការផ្តល់សោហ៊ុយធ្វើដំណើរ ចំនួន ១ដុល្លារក្នុងមួយនាក់សម្រាប់ការទៅរៀនមួយលើក។ អ្នកបានបញ្ចប់វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ ទទួលបានលិខិតបញ្ជាក់ការសិក្សាពី PSE ។

## ការជ្រើសរើសសិស្ស និងការកំណត់ក្រុមក្នុងការសិក្សា

ក្នុងការផ្សព្វផ្សាយ មានការចែកចាយកម្មវិធីបណ្តុះបណ្តាលទៅដល់គ្រួសារនានា និងការបិទប្រកាសនៅតាមកន្លែងសំខាន់ៗក្នុងតំបន់គោលដៅ ប្រមាណ ៣សប្តាហ៍មុនពេលចាប់ធ្វើការបណ្តុះបណ្តាល។ អ្នកចុះឈ្មោះចូលរៀនមានសរុបចំនួន ២៣១នាក់។ ក្នុងវគ្គនីមួយៗ អ្នកចុះឈ្មោះត្រូវបានបែងចែកដោយចៃដន្យតាមសមាមាត្រ ៧០:៣០ ទៅក្នុងក្រុមសម្រាប់វិភាគ (treatment group) និងក្រុមសម្រាប់ត្រួតពិនិត្យ (សម្រាប់ធ្វើការប្រៀបធៀប៖ control group)។ តាមសមាមាត្រនេះ ក្រុមសម្រាប់វិភាគមានចំនួន ១៦២នាក់ និងក្រុមសម្រាប់ត្រួតពិនិត្យមានចំនួន ៦៩នាក់ ។

## ការប្រមូលទិន្នន័យ

ក្រុមស្រាវជ្រាវបានធ្វើអង្កេតពីរ។ ១) ទិន្នន័យអង្កេតដើមគ្រានៅពេលចាប់ផ្តើមការសិក្សា (baseline data) បានប្រមូលយកពីអ្នកចូលរួម ១៨១នាក់ (១២០នាក់ក្នុងក្រុមសម្រាប់វិភាគ និង ៦១នាក់ក្នុងក្រុមសម្រាប់ត្រួតពិនិត្យ) មុនពេលចាប់ផ្តើមវគ្គនីមួយៗ ឬក្នុងសប្តាហ៍ទី១ នៃការបើកថ្នាក់រៀន។ ២) អង្កេតតាមដានបន្ត បានធ្វើឡើង ៥ខែក្រោយវគ្គសិក្សាចប់រួចរាល់ ដោយបានធ្វើសម្ភាសន៍អ្នកចូលរួមចំនួន ១២៥នាក់ (៦៩% នៃចំនួនអ្នកចូលរួមផ្តល់ទិន្នន័យក្នុងអង្កេតដើមគ្រា)។ អត្រាទិន្នន័យមិនអាចប្រមូលបាន (attrition rate) មាន ៣១% គឺប្រហាក់ប្រហែលគ្នានឹង អត្រាទិន្នន័យមិនអាចប្រមូលបានក្នុងការសិក្សាវាយតម្លៃពីផលប៉ះពាល់ស្រដៀងគ្នា នៅតាមប្រទេសកំពុងអភិវឌ្ឍន៍ដទៃទៀត។ អត្រាទិន្នន័យមិនអាចប្រមូលបាននេះ មិនធ្វើឲ្យលំអៀងដល់លទ្ធផលរកឃើញទេ ហើយលក្ខណៈសំគាល់សំខាន់ៗនៃ អ្នកចូលរួមក្នុងការអង្កេតដើមគ្រា ក៏មិនបានជះឥទ្ធិពលទៅលើ អត្រាទិន្នន័យមិនអាចប្រមូលបាននេះដែរ។

## ការប្រៀបធៀបផ្សេងៗក្នុងអង្កេតដើមគ្រា

តេស្តផ្នែកស្ថិតិត្រូវបានធ្វើឡើង សម្រាប់វាយតម្លៃពីភាពអាចប្រៀបធៀបគ្នារវាងក្រុមទាំងពីរ (ក្រុមសម្រាប់វិភាគ និងក្រុមសម្រាប់ត្រួតពិនិត្យ) ដោយប្រើទិន្នន័យអង្កេតដើមគ្រាដើម្បីពិនិត្យថា តើលក្ខណៈសំគាល់ផ្នែកប្រជាសាស្ត្រសំខាន់ៗ និង លទ្ធផលនៃការចូលរួមក្នុងទីផ្សារការងារ វាមានភាពខុសគ្នាគួរឲ្យកត់សំគាល់ឬទេ។ ខ្ទង់៤ ក្នុងតារាង១ បង្ហាញថា លក្ខណៈសំគាល់របស់អ្នកចូលរួមនៅក្នុង ក្រុមសម្រាប់វិភាគ និងក្រុមសម្រាប់ត្រួតពិនិត្យ គឺសឹងដូចគ្នាទាំងស្រុង លើកលែងតែ ចំណុចនៅលីវ ឬរៀបការរួច។ ចំណុចខុសគ្នានេះបានយកមកគិតគូរក្នុងការវិភាគ regression analysis ។

## ការប៉ាន់ស្មានពីឥទ្ធិពលនៃកម្មវិធីបណ្តុះបណ្តាល

ការសិក្សានេះបានគួបផ្សំ ទិន្នន័យអង្កេតដើមគ្រា និងទិន្នន័យអង្កេតតាមដានបន្ត ដើម្បីប៉ាន់ស្មានពី ឥទ្ធិពលនៃការផ្តល់កម្មវិធីបណ្តុះបណ្តាល (intent-to-treat effects) ទៅលើលទ្ធផលជាភាពមានការងារធ្វើ។ បន្ទាប់មកក្រុមស្រាវជ្រាវបានប្រើវិធីសាស្ត្រ instrumental variables two-stage least squares approach ដែលក្នុងនោះការដាក់បញ្ចូលដោយចៃដន្យទៅក្នុង ក្រុមទទួលការបណ្តុះបណ្តាលត្រូវបានប្រើជាឧបករណ៍សម្រាប់បញ្ជាក់ថា បានទទួលការបណ្តុះបណ្តាល ដើម្បីកំណត់នូវ ឥទ្ធិពលនៃការចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាល (treatment-on-treated effect) ។

# លទ្ធផល

## ឥទ្ធិពលនៃការផ្តល់ការបណ្តុះបណ្តាល

កម្មវិធីបណ្តុះបណ្តាល ពុំមានឥទ្ធិពលគួរឲ្យកត់សំគាល់ទេទៅលើ ការទទួលបានការងារធ្វើ ចំនួនម៉ោងធ្វើការ ឬ ប្រាក់ចំណូល (ខ្ទង់១ ក្នុងតារាង២)។ អ្នកចុះឈ្មោះដែលត្រូវបានគេបែងចែកដោយចៃដន្យ ទៅក្នុងក្រុមសម្រាប់វិភាគ មានកំណើនឱកាសទទួលបានការងារធ្វើដល់ប្រមាណ ៨ឯកតាភាគរយ និងចំនួនម៉ោងធ្វើការដល់ ៣ម៉ោង បើធៀបនឹងក្រុមសម្រាប់ត្រួតពិនិត្យ។ ប៉ុន្តែភាពខុសគ្នាទាំងនេះ វាមិនមានសញ្ញាណជាក់ច្បាស់គួរឲ្យកត់សំគាល់នោះទេ។ អ្នកចូលរួមដែលស្ថិតក្នុងក្រុមសម្រាប់ត្រួតពិនិត្យ រកចំណូលបានប្រហែលជា ៥០.០០០រ (១២,៥ដុល្លារ) ក្នុងមួយខែ តិចជាងអ្នកនៅក្នុង

ក្រុមសម្រាប់ត្រួតពិនិត្យ ប៉ុន្តែភាពខុសគ្នានេះ ក៏មិនមានសញ្ញាណជាក់ច្បាស់ គួរឲ្យកត់សំគាល់តាមវិទ្យាសាស្រ្តស្ថិតិនោះដែរ។ វាអាចមកពីអ្នកនៅក្នុងក្រុមសម្រាប់ត្រួតពិនិត្យមានពេលច្រើនជាងសម្រាប់រកការងារធ្វើ រីឯអ្នកនៅក្នុងក្រុមសម្រាប់វិភាគ គឺត្រូវទទួលការបណ្តុះបណ្តាល។

## ឥទ្ធិពលនៃការបានទទួលការបណ្តុះបណ្តាល

ការចូលរួមក្នុងការបណ្តុះបណ្តាល បង្កើនលទ្ធភាពទទួលបានការងារធ្វើ ដែលមានទាំងលទ្ធភាពបានការងារមានប្រាក់កម្រៃ និងអាចបង្កើតមុខរបរដោយខ្លួនឯង ព្រមទាំងមានម៉ោងធ្វើការច្រើន។ ប៉ុន្តែផលជះមកពីការបណ្តុះបណ្តាលនេះមិនមានសញ្ញាណជាក់ច្បាស់ គួរឲ្យកត់សំគាល់តាមវិទ្យាសាស្ត្រស្ថិតិទេ។ ការបណ្តុះបណ្តាលមានឥទ្ធិពលអវិជ្ជមានមួយដែលមិនមានសញ្ញាណ ឲ្យគួរកត់សំគាល់បែបវិទ្យាសាស្រ្តស្ថិតិទេទៅលើប្រាក់ចំណូលប្រចាំខែ។

## ឧបសគ្គរារាំងការចូលរួម និងការបញ្ចប់វគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ

ការសិក្សានេះ បង្ហាញនូវអត្រាបោះបង់ខ្ពស់មុនបញ្ចប់វគ្គបណ្តុះបណ្តាល ដូច្នេះនៅក្នុងអង្កេតតាមដានបន្ត មានការស្រាវជ្រាវពីមូលហេតុនៃ ការបោះបង់ការបណ្តុះបណ្តាលនេះ។ មូលហេតុចម្បងៗមួយចំនួនដែលបានរកឃើញមានដូចតទៅ៖ កាតព្វកិច្ចក្នុងគ្រួសារ (៣១,៩%), គ្មានមធ្យោបាយធ្វើដំណើរទៅ មជ្ឈមណ្ឌលបណ្តុះបណ្តាល (២៣,៤%), រកការងារធ្វើបាន (១៧,០%), គ្មានការផ្តល់ប្រាក់លើកទឹកចិត្តឲ្យចូលរួមក្នុងការបណ្តុះបណ្តាល (៨,៥%), លែងចង់បាន/មិនពេញចិត្តនឹងការបណ្តុះបណ្តាល (៦,៤%), និងមូលហេតុផ្សេងទៀតដូចជា ជំងឺ និងការធ្វើចំណាកស្រុក (១២,៨%)។

## **បទពិសោធន៍រៀនសូត្របានមួយចំនួន**

ការសិក្សានេះ មានបញ្ហាប្រឈមជាច្រើន និងរៀនសូត្របាននូវបទពិសោធន៍មួយចំនួនអំពី ការសាកល្បងតាមវិធីចៃដន្យដោយមានការត្រួតពិនិត្យ ជាពិសេសបទពិសោធន៍ធ្វើការជាមួយក្រុមយុវជនស្ថិតក្នុងស្ថានភាពសេដ្ឋកិច្ចលំបាក។

- បេក្ខជនសិក្ខាកាមខ្លះរារែកខ្លាំងក្នុងការត្រូវបាត់បង់ចំណូលប្រចាំថ្ងៃ (ឧ. ចំណូលបានពីប្រមូល និងលក់របស់អេតចាយ) ទោះបីក្នុងរយៈពេលវែង អាចមានលទ្ធភាពរកចំណូលបានច្រើនឡើងក្តី។ យុវជនខ្លះបានធ្វើចំណាកស្រុកទៅខេត្តផ្សេងដើម្បីធ្វើការងាររយៈពេលខ្លី និងបណ្តោះអាសន្ននៅអំឡុងពេល និងក្រោយពេលបណ្តុះបណ្តាល។
- ការធ្វើដំណើរទៅកាន់មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ជាឧបសគ្គមួយទៀតដែលរារាំងយុវជនស្ថិតក្នុងស្ថានភាពសេដ្ឋកិច្ចលំបាកក្នុងការទៅទទួលការបណ្តុះបណ្តាល។
- យុវជនខ្លះខ្វះបទពិសោធន៍ក្នុងជីវិត និងការងារ ដែលនាំឲ្យមានបញ្ហាអវត្តមាន និងកង្វះទំនួលខុសត្រូវ នៅពេលគេជ្រើសរើសឲ្យចូលធ្វើការ ក្រោយបានបញ្ចប់វគ្គបណ្តុះបណ្តាល។ យុវជនស្ថិតក្នុងស្ថានភាពសេដ្ឋកិច្ចលំបាក ក៏ហាក់ដូចមិនសូវចង់ចំណាយពេលនិងកម្លាំងច្រើន ដើម្បីរកការងារធ្វើដោយខ្លួនឯងដែរ។
- វិទ្យាស្ថាន ឬមជ្ឈមណ្ឌលបណ្តុះបណ្តាលដើរតួនាទីសំខាន់បំផុត ក្នុងការជួយយុវជនឲ្យបញ្ចប់ការបណ្តុះបណ្តាលដោយជោគជ័យ និងក្នុងការតាមដានការរីកចម្រើនរបស់ពួកគេ ក្នុងអំឡុងពេល និងក្រោយពេលបណ្តុះបណ្តាល។
- ថ្វីបើកម្មវិធីបណ្តុះបណ្តាល និងអ្នកផ្តល់ការបណ្តុះបណ្តាលជាកត្តាដ៏សំខាន់ធ្វើឲ្យការបណ្តុះបណ្តាលបានលទ្ធផលល្អក្តី ប៉ុន្តែក៏មិនត្រូវភ្លេចពីសារៈសំខាន់នៃប្រវត្តិគ្រួសារដែរ។ យុវជនខ្លះបានជួបអំពើហិង្សា គ្រឿងញៀន និងអសន្តិសុខក្នុង

តារាង១៖ លក្ខណៈសំគាល់សំខាន់ៗនៃអ្នកចូលរួមក្នុងអង្កេតដើមគ្រា មុនពេលមានអន្តរាគមន៍

| | ចំនួនអ្នកចូលរួមក្នុងការសិក្សាសរុប | ក្រុមសម្រាប់វិភាគ | ក្រុមសម្រាប់ត្រួតពិនិត្យ | ភាពខុសគ្នា |
|---|---|---|---|---|
| | (1) | (2) | (3) | (4 = 2 - 3) |
| លក្ខណៈសំគាល់នៅដើមគ្រា | | | | |
| អាយុ | 20.86<br>[3.63] | 20.70<br>[3.73] | 21.20<br>[3.43] | -0.49<br>(0.69) |
| ប្រុស (=1) | 0.58<br>[0.50] | 0.61<br>[0.49] | 0.51<br>[0.51] | 0.09<br>(0.09) |
| កម្រិតអប់រំ (ឆ្នាំ) | 7.39<br>[3.15] | 7.49<br>[2.96] | 7.20<br>[3.54] | 0.29<br>(0.60) |
| រៀបការរួច (=1) | 0.24<br>[0.43] | 0.17<br>[0.37] | 0.39<br>[0.49] | -0.22**<br>(0.08) |
| បទពិសោធន៍ការងារ (ខែ) | 8.97<br>[20.81] | 8.41<br>[22.33] | 10.12<br>[17.49] | -1.71<br>(3.98) |
| បទពិសោធន៍ក្នុងការបណ្តុះបណ្តាល (=1) | 0.22<br>[0.41] | 0.23<br>[0.42] | 0.20<br>[0.40] | 0.03<br>(0.08) |
| លទ្ធផលពាក់ព័ន្ធនឹងទីផ្សារពលកម្ម | | | | |
| មានការងារធ្វើ | 0.25<br>[0.43] | 0.23<br>[0.42] | 0.29<br>[0.46] | -0.07<br>(0.08) |
| ការងារពេញម៉ោង/ការងារមិនទៀងទាត់ | 0.19<br>[0.40] | 0.18<br>[0.39] | 0.22<br>[0.42] | -0.04<br>(0.08) |
| មុខរបរអនុវត្តឲ្យខ្លួនឯង | 0.06<br>[0.23] | 0.05<br>[0.21] | 0.07<br>[0.26] | -0.03<br>(0.04) |
| ចំនួនម៉ោងធ្វើការ | 10.31<br>[19.38] | 9.48<br>[19.08] | 12.02<br>[20.13] | -2.55<br>(3.70) |
| ប្រាក់ចំណូលប្រចាំខែ (0000៛) | 11.86<br>[22.25] | 11.58<br>[23.06] | 12.44<br>[20.76] | -0.86<br>(4.26) |
| ការសង្កេតពិនិត្យ | 125 | 84 | 41 | |

កំណត់សំគាល់៖ លទ្ធផលសំខាន់សម្រាប់ការសិក្សានេះ គឺថា តើសាមីជនរកបានការងារធ្វើឬទេ។ ក្រុមស្រាវជ្រាវក៏សង្កេតពិនិត្យផងដែរនូវ រង្វាស់ផ្សេងទៀតពាក់ព័ន្ធនឹងទីផ្សារពលកម្ម ដូចជា ស្ថានភាពការងារ ចំនួនម៉ោងធ្វើការ ប្រាក់ចំណូលប្រចាំខែ ជាដើម។ ស្ថានភាពការងារមានរួមបញ្ចូលនូវ "ការងារពេញម៉ោង/ការងារមិនទៀងទាត់" និង "ការបង្កើតមុខរបរឲ្យខ្លួនឯង" ដែលមានតម្លៃ ១ បើសិនពិត និងតម្លៃ 0 បើសិនមិនពិត។ អថេរ "ចំនួនម៉ោងធ្វើការ" បង្ហាញពីចំនួនម៉ោងធ្វើការនៅសប្តាហ៍ចុងក្រោយកន្លងមក ហើយ "ប្រាក់ចំណូលប្រចាំខែ (0000៛)" បង្ហាញនូវ ប្រាក់ចំណូលសរុបក្នុងខែចុងក្រោយ។ គេបានដាក់លេខ 0 ឲ្យ ចំនួនម៉ោងធ្វើការ និងប្រាក់ចំណូលប្រចាំខែ បើសិនសាមីជនរាយការណ៍ថា ខ្លួនគ្មានការងារធ្វើ ឬជាពលករក្នុងគ្រួសារគ្មានបានថ្លៃឈ្នួល ឬជា មេផ្ទះ ឬជា សិស្ស។ Standard deviation មានរាយការណ៍ក្នុងឃ្នាប[ ] ហើយ standard errors មានរាយការណ៍ក្នុងរង្វង់ក្រចក។ ចំនួនមនុស្សក្នុងការវិភាគនេះ គឺជាអ្នកចូលរួមឆ្លើយសម្ភាសន៍ ទាំងនៅក្នុង អង្កេតដើមគ្រា និង អង្កេតតាមដានបន្ត។ ** មានសារៈសំខាន់ផ្នែកស្ថិតិនៅកម្រិត ៥%។

វិទ្យាស្ថាន
បណ្តុះបណ្តាល និង ស្រាវជ្រាវ
ដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ)
អគារលេខ ៥៦ ផ្លូវ ៣១៥ ទួលគោក
ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
+៨៥៥២៣៨៨១៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣
+៨៥៥២៣៨៨០៧៣៤ អ៊ីមែល៖ cdri@cdri.org.kh; www.cdri.org.kh

តារាង២៖ ឥទ្ធិពលនៃការផ្តល់កម្មវិធីបណ្តុះបណ្តាល (intent-to-treat effects: ITT) និងឥទ្ធិពលនៃការចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាល (treatment-on-treated effect: TOT) ក្នុងកម្មវិធីសិក្សាស្រាវជ្រាវនេះ

| អថេរពឹងផ្អែក (Dependent variables) | ឥទ្ធិពល ITT | | ឥទ្ធិពល TOT |
|---|---|---|---|
| | **LPM** (1) | **Probit** (2) | **IV** (3) |
| មានការងារធ្វើ | 0.082 (0.111) | 0.066 (0.108) | 0.193 (0.268) |
| ការងារពេញម៉ោង/ការងារមិនទៀងទាត់ | 0.071 (0.110) | 0.070 (0.107) | 0.160 (0.262) |
| មុខរបរអនុវត្តឲ្យខ្លួនឯង | 0.011 (0.057) | 0.010 (0.054) | 0.033 (0.129) |
| ចំនួនម៉ោងធ្វើការ | 2.834 (6.502) | | 6.689 (16.384) |
| ប្រាក់ចំណូលប្រចាំខែ (0000៛) | -5.020 (6.456) | | -13.494 (15.783) |
| ដំណាក់កាលទី១ F Stat. | | | 54.067*** |
| ការសង្កេតពិនិត្យ | 250 | 250 | 250 |

Notes: This table reports the coefficients of the variable ($TRAINING_i^* t$) for columns 1 and 2. Regressions control for age, education, gender, marital status and recruitment round dummies. For probit regressions in column 2, we use margins with contrast operator in Stata 14 to estimate the average interaction effects. Robust standard errors clustered at the individual level are reported in parentheses. *** significant at 1%.

សង្គម។ ស្ត្រីវ័យក្មេងខ្លះ ត្រូវគោរពតាមសេចក្តីសម្រេចរបស់ប្តីនៅពេលត្រូវជ្រើសរើស រវាងការបណ្តុះបណ្តាលនឹងការបម្រើការងារ។ កង្វះការលើកទឹកចិត្តផ្ទាល់ខ្លួន និងកង្វះការគាំទ្រពីក្រុមគ្រួសារ ក៏នាំឲ្យយុវជនមានការតាំងចិត្តទាបក្នុងការចំណាយពេល និងកម្លាំងក្នុងការធ្វើវិនិយោគលើការអប់រំសិក្សា និងទទួលការបណ្តុះបណ្តាល។ ដូចនេះ វាជាកិច្ចការសំខាន់ ក្នុងការគិតគូរប្រឹងប្រែងបង្កើនការយល់ដឹងរបស់សាធារណជនអំពី អត្ថប្រយោជន៍ដែលអាចទទួលបានពីការធ្វើវិនិយោគលើការអប់រំ និងបណ្តុះបណ្តាលកុមារ។

## ការផ្តល់មតិផ្នែកគោលនយោបាយ

ការវាយតម្លៃតាមបែបពិសោធន៍ជាក់ស្តែង ពីផលប៉ះពាល់នេះ ផ្តល់ផលចំណេញជាច្រើនសម្រាប់កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈនានានៅពេលអនាគត ជាពិសេសក្នុងការកាត់បន្ថយអត្រាបោះបង់ការសិក្សាជំនាញ។ ដើម្បីធានាថាគោលនយោបាយបណ្តុះបណ្តាលជំនាញ កាន់តែធំទូលាយទាំងឡាយ មានលក្ខណៈសម្រាប់ទាំងអស់គ្នា និងមានប្រសិទ្ធភាពកាន់តែខ្ពស់ គួរពិចារណាពីផលពាក់ព័ន្ធផ្នែកគោលនយោបាយដូចតទៅ៖

១. គ្រឿងលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ ដូចជា ការប្រាក់សន្សំ ឬ សកម្មភាពបង្កើតប្រាក់ចំណូលនានា ជាដើម គួរមានដាក់បញ្ចូលក្នុងកម្មវិធីការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ។ វិធីនេះអនុញ្ញាតឲ្យសិក្ខាកាម ទទួលបានបទពិសោធន៍ជីវិតពិតៗ និងបានរៀនសូត្រក្នុងពេលប្រឹងជំនះឧបសគ្គផ្នែកហិរញ្ញវត្ថុ និងការលំបាកផ្សេងៗនៅក្នុងគ្រួសារ។ ការមើលឃើញពីលទ្ធភាពរកបានប្រាក់ចំណូល ជួយលើកទឹកចិត្តសិក្ខាកាមឲ្យយកចិត្តទុកដាក់លើ ការបណ្តុះបណ្តាលជំនាញកាន់តែខ្លាំងឡើង។

២. លទ្ធភាពទទួលយកការបណ្តុះបណ្តាលក៏គួរគិតគូរផងដែរ។ ការផ្តល់ឧបត្ថម្ភធនសម្រាប់ការធ្វើដំណើរ អាចជួយកាត់បន្ថយបញ្ហាអវត្តមាន និងការបោះបង់ការបណ្តុះបណ្តាល ព្រមទាំងបង្កើនអត្រាបញ្ចប់វគ្គសិក្សាជំនាញ។

៣. ស្ថាប័នផ្តល់ ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទាំងឡាយ មិនគួរផ្តោតតែលើ ការផ្តល់ជំនាញគុណភាពខ្ពស់តែមួយមុខនោះទេ ប៉ុន្តែគួរបង្ហាញពីបំណងមោះមុតជួយអភិវឌ្ឍបុគ្គល និងសុខមាលភាពរបស់សិក្ខាកាមផងដែរ។ ការបណ្តុះបណ្តាលលើការត្រៀមស្រេចសម្រាប់ការចូលបំពេញការងារ ការជួយរកកន្លែងធ្វើការឲ្យ ការណែនាំនិងប្រឹក្សាពីមុខរបរនិងអាជីព គួរត្រូវបានធ្វើឡើង ដើម្បីជួយដល់សិក្ខាកាមដែលបានបញ្ចប់វគ្គ ឲ្យចូលទៅក្នុងទីផ្សារការងារ។

៤. វិទ្យាស្ថានបណ្តុះបណ្តាលក៏គួរមានចំណងទាក់ទងរឹងមាំឬភាពជាដៃគូជាមួយវិស័យឧស្សាហកម្មដើម្បីធានាឲ្យសិក្ខាកាម អាចចូលទៅក្នុងទីផ្សារការងារបានដោយរលូន។

៥. ការបណ្តុះបណ្តាលត្រូវឆ្លើយតបនឹងតម្រូវការជាក់ស្តែងនៃទីផ្សារការងារ។ កម្មវិធី និងវិធីសាស្ត្របណ្តុះបណ្តាលគួរមានការកែសម្រួលជាប្រចាំ ដើម្បីអាចតាមទាន់ការផ្លាស់ប្តូរក្នុងរចនាសម្ព័ន្ធសេដ្ឋកិច្ច និងធានាឲ្យការផ្គត់ផ្គង់កម្លាំងពលកម្មឆ្លើយតបតាមតម្រូវការ។

ការសិក្សាស្រាវជ្រាវបន្ថែម ដោយមានចំនួនអ្នកចូលរួមច្រើនជាងនេះគួរធ្វើឡើង ដើម្បីពិនិត្យស្វែងរកមើលថា តើអាចប្រើលទ្ធផលនៃការសិក្សានេះ នៅក្នុងគ្រប់បរិបទផ្សេងទៀតឬទេ។ ទោះយ៉ាងនេះក្តី លទ្ធផលនៃការសិក្សានេះអាចជួយបង្កើនការយល់ដឹងពី ឥទ្ធិពលក្នុងរយៈពេលខ្លីនៃការបណ្តុះបណ្តាលវិជ្ជាជីវៈ ទៅលើទីផ្សារពលកម្មសម្រាប់យុវជននៅកម្ពុជា និងប្រទេសកំពុងអភិវឌ្ឍន៍ផ្សេងទៀត។ ផលប៉ះពាល់ក្នុងរយៈពេលវែងនៃការបណ្តុះបណ្តាល ក៏ត្រូវពិនិត្យតាមដានផងដែរ ដើម្បីពិនិត្យពីអត្រារក្សាសិក្ខាកាមឲ្យរៀនចប់វគ្គបណ្តុះបណ្តាល និងដើម្បីអាចជួយផ្តល់មតិបានកាន់តែជាក់លាក់ឡើងទៀតផ្នែកគោលនយោបាយ៕

## ឯកសារយោង

Ouch Chandarany. 2019. "Vocational Training and Labour Market Transitions: A Randomised Experiment among Cambodian Disadvantaged Young Adults." In *Job Prospects for Youth, Low-skilled and Female Workers in the Greater Mekong Subregion,* edited by Vathana Roth. Phnom Penh. CDRI.